# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


<u>ប្រធានគណៈមេធាវី</u>

មេធាវី ប៊ុន ហុន

<u>ក្រុមប្រឹក្សាគណៈមេធាវី</u>

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ុំ គិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៊ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុកនួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ តិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មានន្ទ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួច
២៣-មេធាវី ទ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ


លេខ : ១២០ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្តីសម្រេចលេខ ០៨៣/សសគម/១៦ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់គណៈមេធាវី ស្តីពីការអនុញ្ញាតឱ្យលោក **អោក ឧត្តម** ចូលប្រកបវិជ្ជាជីវៈមេធាវី
- បានឃើញកំណត់ហេតុសច្ចាប្រណិធានលេខ ១៧/១៦ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍
- យោងតាមសំណើរបស់សាមីខ្លួន
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦។


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

# **សម្រេច**

**ប្រការ ១.-** លោកមេធាវី **សោភ ឧត្តម** អត្តលេខ **១១៨៨ T** ត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សារយៈពេល ១២(ដប់ពីរ)ខែ ជាមួយលោកមេធាវី **សឿង រិទ្ធា** នៅ **ការិយាល័យមេធាវី ធាស៊ាន** ដែលមានអាសយដ្ឋានស្ថិតនៅ**ផ្ទះលេខ ២៥D ផ្លូវលេខ ១៨៧ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះតទៅ។

**ប្រការ ២.-**
- រាល់ទំនាក់ទំនង និងគ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។
- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។
- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច។

**ប្រការ ៣.-** កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនានារបស់គណៈមេធាវី និងចូលរួមគ្រប់សកម្មភាពដែលចាត់តាំងដោយគណៈមេធាវី។

**ប្រការ ៤.-** កម្មសិក្សាការីត្រូវមានកាតព្វកិច្ចជួយការពារក្ដីជូនជនក្រីក្រតាមការចាត់តាំងរបស់គណៈមេធាវី។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក គ្រូកម្មសិក្សា និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមមុខការរៀងៗខ្លួន។

**មេធាវី.ប៊ុន_ហុន**

**ចម្លងជូនៈ**

-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ